សួស្ដី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការផ្ញើអីវ៉ាន់តាមប្រៃសណីយ៍
អញ្ចឹងជាទូទៅប្រសិនបើយើងចង់ផ្ញើអីវ៉ាន់ ឬក៏ផ្ញើអ្វីៗមួយទៅឲ្យអ្នកដទៃ ឬក៏ទៅឲ្យអ្នកណាម្នាក់
នៅក្រៅប្រទេស ឬក៏នៅក្នុងស្រុក យើងតែងតែភាគច្រើនយើងផ្ញើតាមប្រៃសណីយ៍
ប៉ុន្តែពេលខ្លះនៅក្នុងកម្ពុជាគឺ ប្រសិនបើយើងផ្ញើនៅក្នុងស្រុក
បានន័យថាបើយើងផ្ញើពីភ្នំពេញទៅខេត្តផ្សេងៗ ឬក៏ពីខេត្តមួយទៅខេត្តមួយ
គឺយើងអត់សូវប្រើប្រៃសណីយ៍ប៉ុន្មានទេ គឺភាគច្រើនយើងប្រើតាមរយៈឡាន
អញ្ចឹងយើងផ្ញើតាមឡាន តាមស្ថានីយឡានក្រុងជាដើម ក៏ប៉ុន្តែប្រសិនបើយើងផ្ញើទៅក្រៅប្រទេស
អញ្ចឹងយើងផ្ញើតាមប្រៃសណីយ៍ ឬក៏ការិយាល័យប្រៃសណីយ៍ ដើម្បីឲ្យគេផ្ញើទៅក្រៅប្រទេស។

អញ្ចឹងនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានបុរសម្នាក់និងស្ត្រីម្នាក់
អញ្ចឹងមានមនុស្សពីរនាក់នៅក្នុងរូបភាពទី ១ ដែលបុរសម្នាក់នោះ គាត់មានវ័យប្រហែលជា ១៩ ឆ្នាំ
អញ្ចឹងគាត់កំពុងតែកាន់សៀវភៅ ហើយគាត់ឈរទល់មុខនឹងនារីម្នាក់
ប្រហែលជានារីម្នាក់នោះគឺជាមិត្តភក្តិរបស់គាត់ ឬក៏ជាមិត្តស្រីរបស់គាត់ ហើយនារីម្នាក់នោះ
គឺគាត់ពាក់អាវលឿងដៃខ្លី ស្លៀកខោពណ៌ស អញ្ចឹងនារីម្នាក់ហ្នឹងគាត់ចងសក់ទៅក្រោយ
គាត់មានសក់វែង ហើយគាត់ចងសក់ទៅក្រោយ អាយុគាត់ប្រហាក់ប្រហែលគ្នា គឺប្រហែលជា ១៩
ឆ្នាំដូចគ្នា។ អញ្ចឹងក្មេងប្រុសម្នាក់នោះ ឬក៏បុរសម្នាក់ហ្នឹង គាត់ពាក់អាវពណ៌ខៀវដៃខ្លី
ហើយស្លៀកខោពណ៌សដែរ ហើយសក់គាត់ខាងមុខគឺបះឡើងលើ។
អញ្ចឹងដៃគាត់ទាំងពីរកំពុងតែកាន់សៀវភៅ គាត់កាន់សៀវភៅ
ហើយគាត់និយាយទៅប្រាប់នារីម្នាក់នោះថា គាត់ចង់ផ្ញើសៀវភៅនោះទៅឲ្យនរណាម្នាក់
បានន័យថាអាចគាត់ផ្ញើឲ្យមិត្តភក្តិគាត់ផ្សេងទៀត ឬក៏ផ្ញើឲ្យនរណាម្នាក់ទៀតដែលគាត់ស្គាល់
ដែលគេចង់បានសៀវភៅ។ អញ្ចឹងនៅក្នុងរូបភាពទី ១ នេះ បុរសម្នាក់ហ្នឹង គាត់កំពុងតែប្រាប់ទៅនារី
ដែលឈរទល់មុខគាត់ ថាគាត់កំពុងតែចង់ផ្ញើសៀវភៅនេះទៅឲ្យនរណាម្នាក់ដែលនៅក្រៅប្រទេស។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ បន្ទាប់ពីនារីម្នាក់នោះ គាត់ដឹងថា
បុរសដែលជាមិត្តភក្តិរបស់គាត់ហ្នឹងចង់ផ្ញើសៀវភៅទៅក្រៅ ឬក៏ផ្ញើសៀវភៅទៅឲ្យនរណាម្នាក់នោះ
នារីម្នាក់នោះ គាត់ក៏ឲ្យបុរសនោះចាំមួយភ្លែត
ដោយសារតែប្រហែលជាគាត់ចង់ផ្ញើអ្វីមួយទៅឲ្យនរណាម្នាក់ដែរ។
អញ្ចឹងដោយសារតែគាត់អត់ចង់ទៅការិយាល័យប្រៃសណីយ៍ដោយខ្លួនឯង
ដោយសារតែបុរសម្នាក់នោះ គាត់ទៅហើយ។ អញ្ចឹងដោយសារតែមានបុរសម្នាក់នោះគាត់ទៅហើយ
នារីម្នាក់នោះគាត់ឲ្យចាំមួយភ្លែត ព្រោះប្រហែលជាគាត់ត្រូវមានអីវ៉ាន់ផ្ញើដែរ
អញ្ចឹងគាត់ផ្ញើតាមបុរសម្នាក់នោះឲ្យយកទៅការិយាល័យប្រៃសណីយ៍តែម្តង។ អញ្ចឹងនារីម្នាក់នោះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់អត់ចាំបាច់ទៅទេ ដោយឲ្យបុរសម្នាក់នោះ គាត់យកទៅជាមួយទាំងអស់តែម្តង
ដោយសារតែបុរសម្នាក់ហ្នឹង គាត់ត្រូវទៅការិយាល័យប្រៃសណីយ៍
អញ្ចឹងគាត់ត្រូវទៅការិយាល័យប្រៃសណីយ៍ដើម្បីផ្ញើសៀវភៅ ដូច្នេះនារីម្នាក់នោះ
គាត់ក៏ឲ្យបុរសម្នាក់នោះចាំមួយភ្លែត ដើម្បីគាត់ទៅយកអីវ៉ាន់មកដែរ។

បន្ទាប់មកទៀតរូបភាពទី ៣ នៅក្នុងរូបភាពទី ៣ យើងឃើញបន្ទាប់ពីនារីម្នាក់នោះ
គាត់ទៅបានបន្តិច ឬក៏ទៅបានមួយសន្ទុះក្រោយមក អញ្ចឹងគាត់ត្រលប់មកវិញ នារីម្នាក់នោះ
គាត់ក៏ត្រលប់មកវិញ ដោយកាន់នូវសំបុត្រមួយច្បាប់ផងដែរ អញ្ចឹងដោយសារតែនារីម្នាក់នោះ
គាត់ចង់ផ្ញើសំបុត្រទៅឲ្យមិត្តភក្តិរបស់គាត់ ឬក៏ឲ្យទៅក្រុមគ្រួសាររបស់គាត់ដែរ។
ដូច្នេះគាត់ក៏បានយកសំបុត្រនោះមកឲ្យក្មេងប្រុសដែលមានវ័យ ១៩ ឆ្នាំនោះ
យកទៅផ្ញើជាមួយគ្នាតែម្តង ព្រោះក្មេងប្រុសម្នាក់នោះ
គាត់នឹងយកសៀវភៅរបស់គាត់ទៅផ្ញើនៅការិយាល័យប្រៃសណីយ៍ ដើម្បីឲ្យនរណាម្នាក់
ដូច្នេះនៅពេលដែលគាត់ទៅហើយ នារីម្នាក់នោះ
គាត់ក៏បានផ្ញើសំបុត្រមួយទៅដែរតាមបុរសម្នាក់នោះ ដើម្បីយកទៅផ្ញើឲ្យនរណាម្នាក់
ឬក៏ទៅក្រុមគ្រួសារគាត់ អាចជាមិត្តភក្តិរបស់គាត់ដែលនៅឆ្ងាយពីគាត់
អញ្ចឹងគាត់ចង់ផ្ញើសំបុត្រសួរសុខទុក្ខ សំបុត្រនេះអាចជាសំបុត្រសួរសុខទុក្ខគ្នា
ឬក៏អាចសំបុត្រសួរលេងគ្នា បានន័យថាជជែកលេង ដោយសារតែគាត់នឹកមិត្តភក្តិរបស់គាត់
អញ្ចឹងគាត់សរសេរសំបុត្រទៅលេងមិត្តភក្តិរបស់គាត់ អញ្ចឹងគាត់ផ្ញើសំបុត្រនេះទៅឲ្យក្មេងប្រុស
ដែលមានវ័យ ១៩ ឆ្នាំ ដើម្បីយកទៅផ្ញើនៅការិយាល័យប្រៃសណីយ៍។

បន្ទាប់មកទៀតរូបភាពទី ៤ នៅក្នុងរូបភាពទី ៤ បុរសម្នាក់នោះ
គាត់បានដើរមកដល់ការិយាល័យប្រៃសណីយ៍
អញ្ចឹងបន្ទាប់ពីគាត់ទទួលបានសំបុត្រពីនារីដែលជាមិត្តភក្តិរបស់គាត់ហើយ
គាត់ក៏បានកាន់សំបុត្រនោះដើរមកកាន់ការិយាល័យប្រៃសណីយ៍។
ដែលយើងឃើញនៅក្នុងរូបភាពនេះគឺគាត់កំពុងតែដើរមក
អញ្ចឹងគាត់ដើរមកដោយដៃឆ្វេងរបស់គាត់កាន់សំបុត្ររបស់នារីម្នាក់នោះ
ហើយដៃស្តាំរបស់គាត់គឺកាន់សៀវភៅ ដែលយើងឃើញសៀវភៅរបស់គាត់មានច្រើនក្បាល
មានច្រើនក្បាល មានប្រាំក្បាល។ អញ្ចឹងសៀវភៅដែលគាត់កាន់មានបួនក្បាល
ហើយគាត់កាន់សំបុត្រមួយច្បាប់ផងដែរ ហើយដើរមកកាន់ការិយាល័យប្រៃសណីយ៍
ដោយយើងឃើញនៅក្នុងរូបភាពនេះ
នៅក្បែរគាត់គឺយើងឃើញមានខ្លោងទ្វារការិយាល័យប្រៃសណីយ៍ ដែលទ្វារនោះកំពុងតែបើក

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបានន័យថាការិយាល័យប្រៃសណីយ៍គឺបើកទ្វារ
ដើម្បីរង់ចាំស្វាគមន៍អតិថិជនចូលទៅផ្ញើរបស់របរ ឬក៏ផ្ញើសំបុត្រ ឬក៏ផ្ញើអីវ៉ាន់ផ្សេងៗ។
ដោយយើងឃើញនៅខាងលើខ្លោងទ្វារនោះ
យើងឃើញមានសរសេរដាក់ការិយាល័យប្រៃសណីយ៍ផងដែរ
ហើយនៅខាងក្នុងគឺជាបញ្ជរសម្រាប់ទទួលអីវ៉ាន់ ឬក៏ទទួលសម្ភារៈផ្សេងៗដែលយើងចង់ផ្ញើ។
អញ្ចឹងយើងចូលទៅក្នុងការិយាល័យប្រៃសណីយ៍ដោយទៅរកបញ្ជរផ្សេងៗដែលគេចាំទទួលអីវ៉ាន់។

បន្ទាប់មកទៀតរូបភាពទី ៥ រូបភាពទី ៥ គឺនៅក្នុងកន្លែងមួយចំនួនដែលទំនើប
បានន័យថាការិយាល័យប្រៃសណីយ៍ខ្លះ ដោយសារតែមានភ្ញៀវចូលច្រើនពេក
អញ្ចឹងមានភ្ញៀវចូលច្រើន ដូច្នេះគឺមានប្រអប់ដើម្បីចុចចាប់លេខ អញ្ចឹងដោយសារតែភ្ញៀវច្រើន
ហើយត្រូវឲ្យប្រាកដថាអ្នកមកមុនទទួលបានសេវាមុន បានន័យថាអ្នកមកមុន
គាត់អាចផ្ញើរបស់របរបានមុន អញ្ចឹងគេត្រូវចាប់លេខ ដោយគេអត់ចាំបាច់តម្រង់ជួរគ្នាទេ
ដោយសារតែមានមនុស្សច្រើន ដូច្នេះយើងអាចអង្គុយនៅលើកៅអីបាន
ដោយ[គេ/យើង]គ្រាន់តែទៅចុចយកលេខ ហើយយើងអាចចូលទៅកន្លែងដែលយើងផ្ញើ
នៅពេលដែលគេហៅលេខរបស់យើង។ អញ្ចឹងនៅក្នុងរូបភាពនេះ
យើងឃើញមានម៉ាស៊ីនចុចលេខមួយ ម៉ាស៊ីនចុចលេខ ដែលយើងឃើញមានប្រដាប់ចុច
ឬក៏ប៊ូតុងពណ៌បៃតង ដែលនៅលើម៉ាស៊ីននោះ
អញ្ចឹងយើងគ្រាន់តែយកម្រាមដៃរបស់យើងចុចទៅលើប៊ូតុងពណ៌បៃតងនោះ
នោះលេខនឹងចេញមកឲ្យយើងមិនខាន។ ដោយសារតែមានមនុស្សច្រើននៅក្នុងថ្ងៃនេះ
ដូច្នេះនៅពេលដែលបុរសម្នាក់នោះ គាត់ចុចទៅលើប៊ូតុងចាប់លេខ
គឺយើងឃើញលេខរៀងរបស់គាត់គឺលេខរៀងទី ៦២ អញ្ចឹងគាត់បានចាប់យកលេខរៀងទី ៦២
ដោយសារតែគាត់មកដល់ការិយាល័យប្រៃសណីយ៍នេះ គឺជាមនុស្សទី ៦២
ដែលបានមកដល់នៅក្នុងថ្ងៃនេះ។ ដូច្នេះការិយាល័យប្រៃសណីយ៍គឺរវល់ខ្លាំង
ដោយមានមនុស្សមកច្រើន អញ្ចឹងពេលខ្លះ ទៅកន្លែងខ្លះ គឺយើងអត់ចាប់លេខទេ
គឺយើងឈរតម្រង់ជួរ ក៏ប៉ុន្តែកន្លែងខ្លះទៀត គឺយើងអត់តម្រង់ជួរទេ
បានន័យថាយើងគ្រាន់តែចាប់លេខ ហើយយើងអាចមកអង្គុយនៅលើកៅអីផ្សេងៗបាន
ដោយយើងអត់ចាំបាច់ឈរតម្រង់ជួរទេ ព្រោះយើងមានលេខ
ដូច្នេះនៅពេលដែលយើងដល់លេខរៀង គេនឹងហៅយើងឲ្យចូលទៅកន្លែងផ្ញើតែម្តង។

បន្ទាប់មកទៀតរូបភាពទី ៦ នៅក្នុងរូបភាពទី ៦ យើងឃើញបន្ទាប់ពីគាត់ចាប់លេខហើយ
យើងឃើញមានផ្ទាំងមួយ មានផ្ទាំងមួយសម្រាប់លោតលេខ អញ្ចឹងផ្ទាំងមួយនេះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺជាផ្ទាំងសម្រាប់លោតលេខដែលបញ្ជាក់ថា តើលេខរៀងទីប៉ុន្មានទៅបញ្ជរមួយណា
ដោយយើងឃើញបញ្ជរនៅក្នុងការិយាល័យប្រៃសណីយ៍គឺមានច្រើន បានន័យថាមានច្រើន
ដោយសារតែបញ្ជរនោះគឺរង់ចាំទទួលបម្រើអតិថិជន ព្រោះតែអតិថិជនច្រើន
ដូច្នេះនៅក្នុងការិយាល័យប្រៃសណីយ៍គឺគេត្រូវប្រើប្រាស់ អតិថិជនប្រើប្រាស់បញ្ជរច្រើនដែរ
ដើម្បីទទួលស្វាគមន៍ និងបម្រើសេវាដល់អតិថិជន ដែលជាក់ស្តែងនៅក្នុងរូបភាពទី ៦ នេះ
យើងឃើញផ្ទាំង ឬក៏ផ្ទាំងមួយ ដែលបញ្ជាក់ ដែលលោតលេខអំពីថាលេខរៀងទីប៉ុន្មាន
ទៅបញ្ជរមួយណា ដែលយើងឃើញនៅលើគេ នៅលើគេគឺលេខរៀងទី ៥៩ ទៅបញ្ជរអក្សរ A
អញ្ចឹងបានន័យថាអ្នកណាដែលមាន អ្នកណាដែលចុចបានលេខរៀងទី ៦៩ ៥៩
អញ្ចឹងអ្នកណាដែលចុចបានលេខ ៥៩ គឺយើងត្រូវដើរទៅបញ្ជរ A បញ្ជរអក្សរ A ដើម្បីផ្ញើរបស់របរ
ឬក៏ដើម្បីទទួលសេវាកម្មពីការិយាល័យប្រៃសណីយ៍ ដោយយើងអត់ត្រូវខុសបញ្ជរទេ
យើងអត់ត្រូវទៅខុសបញ្ជរទេ ដោយសារតែពេលខ្លះបញ្ជរគឺរវល់ទាំងអស់
ដូច្នេះយើងទៅតែបញ្ជរណាដែលទំនេរតែប៉ុណ្ណោះ។ អញ្ចឹងនៅពេលដែលបញ្ជរណាទំនេរ
គេនឹងចុចលេខរៀងមួយ គេនឹងប្តូរលេខរៀង ដើម្បីឲ្យអតិថិជនទៅបញ្ជរមួយនោះ
អញ្ចឹងដោយសារតែបញ្ជរអក្សរ A គឺទំនេរ ដូច្នេះលេខរៀងទី ៥៩ ត្រូវទៅបញ្ជរអក្សរ A។
បន្ទាប់មកទៀតយើងឃើញលេខរៀងទី ៦០ គឺត្រូវទៅបញ្ជរអក្សរ B
អញ្ចឹងដោយសារតែបញ្ជរយើងមានច្រើន ដូច្នេះយើងអាចបម្រើសេវាអតិថិជនហ្នឹងបានច្រើននាក់ដែរ
នៅក្នុងមួយដងៗ ដោយសារតែយើងមានបញ្ជរ A បញ្ជរ B ផងដែរ
ដែលភាគច្រើននៅក្នុងប្រទេសកម្ពុជាយើងប្រើប្រាស់បញ្ជរ ក បញ្ជរ ខ បញ្ជរ គ ដោយសារតែអក្សរ
ក អក្សរ ខ អក្សរ គ គឺជាព្យញ្ជនៈនៅក្នុងភាសាខ្មែរនៅក្នុងអក្សរខ្មែរ
ដូច្នេះភាគច្រើននៅក្នុងការបម្រើសេវាកម្មនៅក្នុងប្រទេសកម្ពុជា គឺយើងប្រើប្រាស់អក្សរខ្មែរ
ដូចជាអក្សរ ក អក្សរ ខ អក្សរ គ។ ដែលយើងឃើញនៅក្នុងរូបភាពនេះ គឺនៅក្រោមគេ
គឺលេខរៀងទី ៦១ គឺគេត្រូវឲ្យទៅបញ្ជរអក្សរ A អញ្ចឹងដោយសារតែលេខរៀងទី ៥៩
ដោយសារលេខរៀងទី ៥៩ គាត់បានបញ្ចប់ការប្រើប្រាស់សេវារបស់គាត់នៅបញ្ជរអក្សរ A ហើយ
ដូច្នេះនៅពេលដែលគាត់ទំនេរ អញ្ចឹងគេចុចលេខរៀងបន្តទៀត អញ្ចឹងដោយសារតែលេខរៀងទី ៦០
ទៅដល់បញ្ជរ B ដូច្នេះយើងឆ្លងទៅដល់លេខរៀងទី ៦១ តែម្តង គឺត្រូវទៅបញ្ជរអក្សរ A ដដែល។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញ បុរសម្នាក់នោះ
ដោយសារតែគាត់កាន់លេខរៀងទី ៦២ អញ្ចឹងនៅពេលដែលដល់លេខរៀងទី ៦២ បុរសម្នាក់នោះ
គាត់ក៏ដើរចូលទៅបញ្ជរ B អញ្ចឹងយើងឃើញនៅក្បែរបញ្ជរនោះគឺមានផ្ទាំងលេខរៀង
ដែលយើងឃើញលេខ ៦២ របស់បុរសដែលពាក់អាវខៀវហ្នឹង គឺនៅបញ្ជរអក្សរ B
ដូច្នេះបុរសម្នាក់នោះ គាត់ក៏បានកាន់សៀវភៅរបស់គាត់ ដើម្បីទៅបញ្ជរអក្សរ B

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដែលយើងឃើញអក្សរ A និងអក្សរ B គឺនៅជាប់គ្នា បានន័យថាបញ្ជរអក្សរ A និងបញ្ជរអក្សរ B គឺនៅជាមួយគ្នាតែម្តង គឺនៅជាប់គ្នា ដូច្នេះយើងឃើញមានបុរសម្នាក់ គាត់កំពុងតែឈរនៅបញ្ជរអក្សរ A ដើម្បីផ្ញើរបស់របរ ឬក៏ដើម្បីទទួលរបស់របរដែលគេផ្ញើមក។ អញ្ចឹងដោយសារតែការិយាល័យប្រៃសណីយ៍គឺមានអតិថិជនច្រើន ដូច្នេះយើងឃើញមានបុរសម្នាក់ ដែលពាក់អាវស ខោស គាត់កំពុងតែឈរនៅខាងមុខបញ្ជរអក្សរ A ដើម្បីរង់ចាំទទួលសេវាកម្ម គាត់អាចមកទីនេះដើម្បីទទួលយករបស់ ឬក៏ទទួលយកបញ្ញើពីមិត្តភក្តិរបស់គាត់ ឬក៏ពីក្រុមគ្រួសាររបស់គាត់ដែលផ្ញើមក ឬក៏គាត់អាចយករបស់របរទៅផ្ញើទៅក្រុមគ្រួសាររបស់គាត់ ឬក៏មិត្តភក្តិរបស់គាត់ ដែលនៅខាងក្រៅ ឬក៏ដែលនៅឆ្ងាយពីគាត់ ដូច្នេះដោយសារតែលេខរៀងរបស់គាត់គឺត្រូវមកបញ្ជរអក្សរ A ដូច្នេះគាត់ក៏មក ដើរមក តម្រង់មកអក្សរ A ប៉ុន្តែដោយសារតែក្មេងប្រុសដែលមានវ័យ ១៩ ឆ្នាំម្នាក់នេះ លេខរៀងទី ៦២ ហើយលេខរៀងទី ៦២ គឺគេបង្ហាញឲ្យមកបញ្ជរអក្សរ B ដូច្នេះគាត់ក៏បានកាន់សៀវភៅនិងសំបុត្ររបស់គាត់ដើរមកកាន់បញ្ជរអក្សរ B ដោយយើងឃើញនៅក្នុងបញ្ជរអក្សរ B យើងឃើញមានបុរសម្នាក់ ដែលជាបុគ្គលិកបម្រើការនៅក្នុងការិយាល័យប្រៃសណីយ៍នោះ គឺគាត់កំពុងតែអង្គុយដើម្បីរង់ចាំអតិថិជន។ អញ្ចឹងគាត់អង្គុយនៅក្នុងនោះដោយស្លៀកសម្លៀកបំពាក់ឯកសណ្ឋាន អញ្ចឹងគាត់ស្លៀកឯកសណ្ឋានជាអ្នកធ្វើការនៅក្នុងការិយាល័យប្រៃសណីយ៍ ដើម្បីទទួលបញ្ញើពីអតិថិជន ហើយយើងឃើញនៅក្បែរគាត់គឺមានតុដាក់សម្ភារៈជាច្រើន បានន័យថាគាត់មានឯកសារជាច្រើននៅក្នុងបញ្ជររបស់គាត់ ដែលគាត់ទទួលបញ្ញើ ដូច្នេះគាត់កំពុងតែអង្គុយដើម្បីផ្តល់សេវាកម្មទៅឲ្យអតិថិជនរបស់គាត់ ដែលចង់ផ្ញើរបស់របរ ឬក៏ចង់មកទទួលរបស់របរដែលគេបានផ្ញើ។

បន្ទាប់មកទៀតរូបភាពទី ៨ រូបភាពទី ៨ គឺការផ្ញើរបស់របរនៅក្នុងការិយាល័យប្រៃសណីយ៍ គឺយើងបែងចែកចេញជាពីរ គឺការផ្ញើរបស់របរជាសំបុត្រ ការផ្ញើសំបុត្រផ្សេង និងការផ្ញើរបស់របរជាអីវ៉ាន់ផ្សេង ដោយសារតែសំបុត្រគឺយើងត្រូវយកសំបុត្រនោះទៅបិទតែមសិន អញ្ចឹងយើងបិទតែមប្រៃសណីយ៍សិន ជាមុនសិន មុននឹងយើងអាចយកទៅផ្ញើបាន ដូច្នេះនៅក្នុងរូបភាពទី ៨ គឺយើងឃើញក្មេងប្រុសម្នាក់ហ្នឹង គាត់ក៏បានយកសំបុត្ររបស់នារីម្នាក់ ដែលផ្ញើតាមគាត់មកប្រៃសណីយ៍ហ្នឹង យកទៅបិទតែម អញ្ចឹងជាទូទៅតែមប្រៃសណីយ៍ គឺយើងមានតែមជាច្រើនប្រភេទទៅតាមតម្លៃ និងទៅតាមអ្វីដែលយើងចង់ផ្ញើ ដោយតែមខ្លះមានតម្លៃ ១០០ រៀល តែមខ្លះមានតម្លៃ ៥០០ រៀល តែមខ្លះមានតម្លៃ ១០០០ រៀល អញ្ចឹងទៅតាមប្រភេទតែមនិងទៅតាមគោលដៅដែលគេត្រូវផ្ញើ។ ដូច្នេះប្រសិនបើគេផ្ញើជិត

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺយើងអាចបិទតែម ១០០ រៀល ឬក៏ ៥០០ រៀល ក៏ប៉ុន្តែប្រសិនបើយើងត្រូវផ្ញើទៅឆ្ងាយ
សំបុត្រនេះត្រូវផ្ញើទៅប្រទេសឆ្ងាយ ឬក៏ផ្ញើទៅកន្លែងឆ្ងាយ គឺគេអាចបិទតែម ១០០០ រៀល
ឬក៏គេអាចបិទតែមទាំងអស់តែម្តង គឺពេលខ្លះ គឺគេបិទតែមប្រៃសណីយ៍ទាំងអស់តែម្តង
គឺបិទទាំងតែម ១០០ រៀល បិទទាំងតែម ៥០០ រៀល ក៏ដូចជាបិទទាំងតែម ១០០០
រៀលជាមួយនឹងគ្នាតែម្តង បានន័យថាគេបិទតែមចំនួនបី ក៏ប៉ុន្តែនៅក្នុងរូបភាពនេះ
គឺយើងឃើញគាត់បិទតែមចំនួនមួយតែប៉ុណ្ណោះ
អញ្ចឹងគាត់យកតែមមកបិទទៅលើស្រោមសំបុត្ររបស់គាត់ ក៏ប៉ុន្តែគាត់អត់បិទឲ្យចំតួអក្សរនោះទេ
ដោយសារតែលើសំបុត្រនេះយើងឃើញមានអក្សរ ដើម្បីសរសេរឈ្មោះអ្នកទទួលសំបុត្រនោះ
ក៏ដូចជាអាសយដ្ឋានរបស់អ្នកទទួលសំបុត្រ អញ្ចឹងដើម្បីផ្ញើសំបុត្រ
យើងត្រូវសរសេរឈ្មោះនិងអាសយដ្ឋានរបស់អ្នកទទួលឲ្យបានច្បាស់លាស់
ដើម្បីងាយស្រួលឲ្យគេយកសំបុត្រនោះទៅឲ្យអ្នកដែលត្រូវទទួល
ព្រោះប្រសិនបើយើងអត់សរសេរឈ្មោះគាត់ទេ អញ្ចឹងយើងអត់
ប្រសិនបើយើងអត់បញ្ជាក់ពីអាសយដ្ឋាននិងឈ្មោះរបស់គាត់ទេ អ្នករត់សំបុត្រ
យើងហៅថាអ្នករត់សំបុត្រ ពិបាកនៅក្នុងការរកអ្នកដែលទទួលសំបុត្រខ្លាំងណាស់
ដោយសារតែអត់មានឈ្មោះនិងអត់មានអាសយដ្ឋានត្រឹមត្រូវ ដូច្នេះនៅក្នុងរូបភាពនេះ
គាត់កំពុងតែបិទតែមមិនឲ្យចំតួអក្សរ ឬក៏មិនឲ្យចំឈ្មោះអ្នកទទួលនោះទេ ដើម្បីកុំឲ្យបាំង។
បន្ទាប់មកទៀតយើងឃើញគាត់បានវ៉ៃត្រា បោះត្រាទៅលើតែមនោះ
អញ្ចឹងក្នុងការបោះត្រាក៏គេមានរបៀបបោះត្រារបស់គេដែរ ដោយយើងឃើញការបោះត្រា
គឺយើងត្រូវបោះពាក់កណ្តាលនៅលើតែម ហើយពាក់កណ្តាលទៀតគឺត្រូវហៀរមកលើសំបុត្រ
ដើម្បីបញ្ជាក់ថាតែមមួយនោះគឺប្រើប្រាស់រួចរាល់ហើយ
អញ្ចឹងយើងអត់អាចយកតែមនោះទៅប្រើប្រាស់ម្តងទៀតបានទេ អញ្ចឹងជាទូទៅតែមប្រៃសណីយ៍
គឺយើងប្រើប្រាស់តែម្តងតែប៉ុណ្ណោះ ដោយយើងបិទហើយ យើងបោះត្រាពីលើ ដែលត្រាជាទូទៅ
ត្រាដែលបោះលើតែមប្រៃសណីយ៍ គឺយើងបោះត្រាមោឃៈ អញ្ចឹងមោឃៈ បានន័យថា
យើងប្រើប្រាស់លែងបានទៀតហើយ បានន័យថាតែមនោះ គឺលែង
លែងមានប្រសិទ្ធិភាពប្រើទៀតហើយ នៅពេលដែលយើងប្រើបានម្តង
ដោយយើងឃើញនៅក្នុងរូបភាពនេះ ត្រាគឺរាងមូល ត្រារបស់គាត់ដែលកាន់គឺមានរាងមូល
ដែលរាងមូលសំប៉ែតនៅខាងក្រោម អញ្ចឹងសំប៉ែតនៅខាងក្រោមគឺគេប្រើជាប្លាស្ទិក
ដើម្បីជ្រលក់ពណ៌ ហើយបោះនៅលើក្រដាស ដែលសរសេរជាអក្សរផ្សេងៗ
ដូចជាសរសេរជាអក្សរមោឃៈជាដើម ហើយយើងឃើញមានដងកាន់បន្តិច
អញ្ចឹងត្រាគឺតែងតែមានដងកាន់ ដើម្បីឲ្យយើងងាយស្រួលកាន់ក្នុងការបោះត្រា
ដោយយើងឃើញគាត់ប្រើប្រាស់ម្រាមដៃរបស់គាត់ចាប់កាន់ដងត្រា

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ហើយបោះត្រាទៅលើតែមជាមួយនឹងសំបុត្រ អញ្ចឹងគាត់បោះអត់ឲ្យចំលើតែមសុទ្ធ ឬក៏ចំលើសំបុត្រសុទ្ធទេ ដោយគាត់ យើងឃើញស្នាមតែមដែលគាត់បោះនោះ គឺមានបន្តិចជាប់នៅពាក់កណ្ដាល ជាប់នៅលើតែម ហើយពាក់កណ្ដាលទៀតគឺជាប់នៅលើសំបុត្រ អញ្ចឹងគឺតែមនោះគឺ យើងបោះត្រានោះគឺ ដើម្បីបញ្ជាក់ថា តែមនោះប្រើប្រាស់លែងបានទៀតហើយ។

បន្ទាប់មកទៀតរូបភាពទី ៩ រូបភាពទី ៩ យើងឃើញថា បន្ទាប់ពីគាត់បោះត្រាតែមសំបុត្រហើយ គាត់ក៏បានផ្ញើសំបុត្រនោះទៅដល់អ្នកលក់ ទៅឲ្យទៅបុគ្គលិកដែលបម្រើការងារនៅក្នុងការិយាល័យប្រៃសណីយ៍ ហើយបន្ទាប់មកទៀតសៀវភៅរបស់គាត់ មុននឹងគាត់អាចផ្ញើចេញ គាត់ត្រូវខ្ចប់វាជាមុនសិន ដូច្នេះគាត់ក៏បានដើរមករកបុគ្គលិកដែលនៅក្នុងការិយាល័យប្រៃសណីយ៍មួយទៀត ដើម្បីស្វែងរកកញ្ចប់ អញ្ចឹងយើងមានក្រដាសកេស ឬក៏ក្រដាសឡាំងមួយ ដែលយើងឃើញបុរសម្នាក់នោះ គាត់ក៏បានមកទិញក្រដាសឡាំងមួយ ដើម្បីខ្ចប់សៀវភៅរបស់គាត់ ដោយយើងឃើញអ្នកលក់ គឺគាត់ពាក់អាវពណ៌ប្រផេះដៃខ្លី ហើយគាត់រាងចំណាស់បន្តិច សក់របស់គាត់គឺសិតរាប បានន័យថាគាត់សិតវែកភ្លីរាប ហើយគាត់មានវ័យប្រហែលជា ៣៥ ឆ្នាំ ដែលបុរសម្នាក់នោះ គាត់កំពុងតែយកឡាំងក្រដាសមួយ ឬក៏សំបកឡាំង ឬក៏ក្រដាសការតុង ដើម្បីយកមកឲ្យក្មេងប្រុសម្នាក់នោះខ្ចប់សៀវភៅរបស់គាត់ ក៏ប៉ុន្តែក្រដាសឡាំងនេះ គឺគេមិនមែនឲ្យដោយឥតគិតថ្លៃទេ អញ្ចឹងក្រដាសឡាំង គេអត់ឲ្យដោយគេឥតគិតថ្លៃទេ ដោយគេលក់ អញ្ចឹងប្រសិនបើយើងអត់ចង់ចំណាយលុយច្រើន ដើម្បីទិញក្រដាសឡាំងនៅការិយាល័យប្រៃសណីយ៍ទេ យើងអាចខ្ចប់សៀវភៅរបស់យើង ឬក៏អាចខ្ចប់អីវ៉ាន់របស់យើងមកពីផ្ទះឲ្យហើយ អញ្ចឹងយើង នៅពេលមកដល់ យើងគ្រាន់តែដាក់ផ្ញើជាការស្រេច។ ក៏ប៉ុន្តែដោយសារតែក្មេងប្រុសម្នាក់នេះ គាត់អត់បានខ្ចប់សៀវភៅរបស់គាត់មកពីផ្ទះទេ ដូច្នេះប្រសិនបើគាត់ចង់ផ្ញើគឺគេត្រូវខ្ចប់អីវ៉ាន់របស់គាត់ ឬក៏សៀវភៅរបស់គាត់ជាមុនសិន ទើបគាត់អាចផ្ញើទៅបាន ព្រោះប្រសិនបើគាត់អត់ខ្ចប់ទេ អីវ៉ាន់គាត់ច្រើន នៅពេលដែលអីវ៉ាន់គាត់ច្រើនបែបនេះ គឺវាអាចនឹងរញ៉េរញ៉ៃ ដូច្នេះគេត្រូវខ្ចប់ឲ្យមានសណ្ដាប់ធ្នាប់ ព្រោះពេលខ្លះ ប្រសិនបើយើងអត់ខ្ចប់ អីវ៉ាន់របស់យើងអាចនឹងខ្ទេច ដូចជាអាចនឹងរហែក ឬក៏អាចនឹងខូច ដោយសារតែមានរបស់ច្រើនដែលគេត្រូវផ្ញើ ដូច្នេះគឺគេដាក់គរលើគ្នា អញ្ចឹងរបស់ អីវ៉ាន់របស់យើងអាចនឹងខូច ដូច្នេះក្មេងប្រុសម្នាក់នេះនៅក្នុងរូបភាពទី ៩ គាត់ក៏បានមកទិញឡាំងក្រដាសមួយ សំបកឡាំងក្រដាសមួយពីបុគ្គលិក ដែលនៅក្នុងការិយាល័យប្រៃសណីយ៍ ដើម្បីខ្ចប់សៀវភៅរបស់គាត់។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ១០ នៅក្នុងរូបភាពទី ១០
បន្ទាប់ពីគាត់បានទទួលសំបកឡាំងក្រដាសរួចរាល់ហើយ អញ្ចឹងក្មេងប្រុសម្នាក់នោះ
គាត់ក៏បានប្រគល់លុយថ្លៃឡាំងក្រដាសនោះទៅឲ្យបុគ្គលិកប្រៃសណីយ៍វិញ
ដូច្នេះដោយសារតែគាត់ទិញ ដោយសារតែឡាំងក្រដាសនោះមិនមែនគេផ្ដល់ឲ្យដោយឥតគិតថ្លៃទេ
អញ្ចឹងដោយសារតែគាត់ទិញឡាំងក្រដាសនោះ ដូច្នេះគាត់ត្រូវឲ្យលុយ
នៅពេលដែលគាត់ទទួលបានឡាំងក្រដាសនោះរួចរាល់
មុននឹងគាត់ចាកចេញទៅខ្ចប់សៀវភៅរបស់គាត់ ដោយយើងឃើញនៅក្នុងរូបភាពនេះគឺគាត់
ដៃស្ដាំរបស់គាត់គឺគាត់កាន់សៀវភៅរបស់គាត់ដដែល អញ្ចឹងគាត់អត់ដាក់សៀវភៅរបស់គាត់ចុះទេ
គឺគាត់នៅតែកាន់សៀវភៅរបស់គាត់ដែលគាត់ឱបទៅនឹងខ្លួន
បានន័យថាគាត់ឱបសៀវភៅរបស់គាត់ទៅនឹងខ្លួន
ដោយយកដៃកាន់ឬក៏ខ្ចប់សៀវភៅដែលនៅក្រោមគេ
ហើយសៀវភៅផ្សេងទៀតគឺគាត់យកខ្ចប់ទៅនឹងខ្លួន បានន័យថាគាត់យកខ្លួនគាត់ទប់នឹងសៀវភៅ
ដើម្បីកុំឲ្យសៀវភៅជ្រុះ ដូច្នេះយើងឃើញដៃឆ្វេងរបស់គាត់
គឺកំពុងតែកាន់លុយហុចទៅឲ្យបុគ្គលិកនៅការិយាល័យប្រៃសណីយ៍នោះ
ហើយដែលយើងឃើញបុគ្គលិកនៅក្នុងការិយាល័យប្រៃសណីយ៍នោះ
គាត់ក៏បានលូកដៃទទួលលុយថ្លៃឡាំងក្រដាសនោះពីក្មេងប្រុសម្នាក់នោះផងដែរ។

បន្ទាប់មកទៀតរូបភាពទី ១១ នៅក្នុងរូបភាពទី ១១ យើងឃើញក្មេងប្រុសម្នាក់នោះ
គាត់ក៏បានដើរមករកកន្លែងខ្ចប់អីវ៉ាន់ បានន័យថានៅក្នុងការិយាល័យប្រៃសណីយ៍
គឺគេតែងតែមានតុមួយសម្រាប់ឲ្យយើងខ្ចប់អីវ៉ាន់ ដូច្នេះនៅពេលដែលយើងទិញឡាំងក្រដាសហើយ
នៅពេលដែលក្មេងប្រុសម្នាក់នោះ គាត់ទិញឡាំងក្រដាសហើយ
គាត់ក៏បានកាន់ឡាំងក្រដាសជាមួយនឹងសៀវភៅរបស់គាត់នោះមករកតុមួយ
អញ្ចឹងនៅក្នុងរូបភាពនេះយើងឃើញមានតុមួយ
ដែលនៅលើតុនោះគឺយើងឃើញមានក្រដាសកាសែត យើងឃើញមានដូចជាកាវ កាវស្អិត
ហើយនិងស្កុតផងដែរ។
អញ្ចឹងគឺការិយាល័យប្រៃសណីយ៍គឺគេតែងតែដាក់ឧបករណ៍ផ្សេងៗសម្រាប់ខ្ចប់អីវ៉ាន់នៅលើតុ
ដើម្បីឲ្យអតិថិជនប្រើប្រាស់ អញ្ចឹងយើងអត់ចាំបាច់យកស្កុត
អត់ចាំបាច់យកកាវទៅផ្ទាល់ខ្លួនទៅក៏បានដែរ ដោយនៅទីនោះគឺគេមានដាក់ឲ្យយើងស្រាប់តែម្ដង
អញ្ចឹងគឺគេដាក់នៅលើតុដើម្បីឲ្យអតិថិជនទាំងអស់ប្រើប្រាស់
ដោយនៅពេលដែលយើងប្រើប្រាស់ហើយ យើងគ្រាន់តែដាក់នៅលើតុនោះវិញ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីឲ្យអ្នកផ្សេងទៀតមកប្រើដោយយើងអត់ត្រូវយកនោះទេ
ដោយសារតែរបស់នេះគឺគេដាក់ប្រើរួម ជារបស់រួម ដូច្នេះអ្នកណាក៏មានសិទ្ធិប្រើផងដែរ
អញ្ចឹងក្មេងប្រុសម្នាក់ហ្នឹង គាត់ក៏បានកាន់ឡាំងក្រដាសជាមួយនឹងសៀវភៅមករកតុខ្ចប់អីវ៉ាន់
ដែលយើងឃើញនៅក្រោមតុគឺមានធុងសំរាមមួយ អញ្ចឹងដោយសារតែនៅពេលដែលយើងខ្ចប់អីវ៉ាន់
គឺតែងតែមានសំរាម ដូចជាស្កុតដែលនៅសល់ ឬក៏ក្រដាសកាសែតដែលនៅសល់
ដូច្នេះគឺយើងអត់បោះចោលពាសវាលពាសកាលទេ អញ្ចឹងដើម្បីរក្សាអនាម័យ
និងដើម្បីរក្សាសណ្ដាប់ធ្នាប់ គឺយើងត្រូវបោះសំរាមចូលទៅក្នុងធុងសំរាម អញ្ចឹងក្មេងប្រុសម្នាក់នេះ
គាត់ក៏បានកាន់ឡាំងក្រដាសរបស់គាត់ ដើម្បីមកខ្ចប់អីវ៉ាន់នៅលើតុមួយ។

បន្ទាប់មកទៀតរូបភាពទី ១២ រូបភាពទី ១២
គាត់ក៏បានបត់ក្រដាសឡាំងរបស់គាត់ឲ្យទៅជារាងប្រអប់មួយ
អញ្ចឹងដោយសារតែឡាំងក្រដាសអម្បាញ់មិញគឺអត់ទាន់មានបត់ចេញជារូបរាងប្រអប់ទេ
ដូច្នេះគាត់ត្រូវតែយកឡាំងក្រដាសនោះមកបត់ចេញជារាងប្រអប់មួយដើម្បីដាក់សៀវភៅ
អញ្ចឹងដោយសារតែនៅលើតុ នៅលើតុគឺមានស្កុត ក៏ដូចជាមានកាវសម្រាប់បិទហើយ
ដូច្នេះគាត់គ្រាន់តែយកឡាំងក្រដាសរបស់គាត់មកបត់ជ្រុងៗឲ្យចេញជារាងប្រអប់
ហើយលើកជ្រុងៗរបស់ឡាំងក្រដាសនោះឡើងផ្គុំចូលគ្នា
បន្ទាប់មកគាត់យកស្កុតមកបិទជាការស្រេច អញ្ចឹងនៅក្នុងរូបភាពទី ១២ នេះ
គាត់កំពុងតែផ្គុំឡាំងក្រដាសនោះឲ្យចេញជារាងប្រអប់មួយ ដើម្បីដាក់សៀវភៅចូលទៅខាងក្នុង
ដោយគាត់ប្រើប្រាស់ស្កុតដើម្បីបិទ ឬក៏ប្រើប្រាស់កាវដើម្បីបិទឲ្យវាជាប់គ្នា
អញ្ចឹងដោយសារតែនៅការិយាល័យប្រៃសណីយ៍គេអត់ដឹងទំហំសម្ភារៈ
ឬក៏ទំហំរបស់របរដែលយើងចង់ផ្ញើ ដូច្នេះគឺគេអត់លក់ជាប្រអប់នោះទេ
គឺគេលក់ជាក្រដាសឡាំងតែម្ដង ដើម្បីឲ្យយើងបត់ខ្លួនឯង
ព្រោះដើម្បីឲ្យយើងប៉ាន់ស្មានថាតើទំហំប៉ុណ្ណា ត្រឹមត្រូវជាមួយនឹងទំហំរបស់សម្ភារៈរបស់យើង
អញ្ចឹងនៅក្នុងរូបភាពនេះ ក្មេងប្រុសម្នាក់នោះ
គាត់ក៏បានកំពុងតែបត់ឡាំងក្រដាសនោះឲ្យចេញជាប្រអប់មួយ ដើម្បីដាក់សៀវភៅចូលទៅខាងក្នុង
ដោយគាត់ប្រើប្រាស់ស្កុត ឬក៏កាវ ដើម្បី ដើម្បីបិទឡាំងក្រដាសនោះឲ្យជាប់គ្នា។

បន្ទាប់មកទៀតរូបភាពទី ១៣ នៅក្នុងរូបភាពទី ១៣
បន្ទាប់ពីគាត់ផ្គុំឡាំងក្រដាសនោះចេញជារូបរាងប្រអប់មួយហើយ
អញ្ចឹងគាត់ក៏បានដាក់សៀវភៅរបស់គាត់ទាំងអស់ចូលទៅក្នុងឡាំងក្រដាសនោះតែម្ដង
ដោយយើងឃើញគាត់លើកសៀវភៅរបស់គាត់ដោយដៃទាំងពីរ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់លើកសៀវភៅរបស់គាត់ដោយដៃទាំងពីរ
ហើយលើកសៀវភៅនោះមកដាក់ចូលនៅក្នុងប្រអប់ឡាំងក្រដាសនោះ
ដោយគាត់ទើបតែធ្វើអម្បាញ់មិញ អញ្ចឹងគាត់ដាក់ចូលដើម្បីខ្ចប់វាផ្ញើទៅមិត្តភក្តិរបស់គាត់
ដែលនៅខាងក្រៅ ឬក៏ដើម្បីផ្ញើទៅគ្រួសាររបស់គាត់ ដោយគាត់រៀបចំឲ្យបានស្អាតបាត
មុននឹងគាត់ផ្ញើចេញ ដើម្បីឲ្យប្រាកដថាសៀវភៅនោះគឺមិននឹងខូចខាតនៅពេលដែលគេផ្ញើ។

បន្ទាប់មកទៀតរូបភាពទី ១៤ នៅក្នុងរូបភាពទី ១៤ យើងឃើញ ដោយសារតែឡាំងក្រដាសនោះ
វាមានទំហំធំជាងសៀវភៅបន្តិច ដូច្នេះក្មេងប្រុសម្នាក់នោះ
គាត់ក៏បានយកក្រដាសកាសែតមកសៀតនៅសងខាង នៅខាងៗ
ដើម្បីឲ្យសៀវភៅនោះណែនល្អទៅនឹងប្រអប់ឡាំងក្រដាសនោះ អញ្ចឹងដោយសារតែឡាំងក្រដាស
ដោយសារតែសៀវភៅវាតូចជាងឡាំងក្រដាសនោះបន្តិច វាតូចជាងប្រអប់នោះបន្តិច
អញ្ចឹងវាធ្វើឲ្យរលុង បានន័យថាសៀវភៅនោះនឹងរលុងនៅពេលដែលគេខ្ចប់
អញ្ចឹងវាអាចក្រឡុកចុះឡើងៗ ទៅឆ្វេងទៅស្តាំបាន វានឹងរង្គើ នៅពេលដែលគេដឹកជញ្ជូន
ឬក៏វាអាចធ្វើឲ្យខូចឡាំងក្រដាសនោះបាន នៅពេលដែលគេដាក់អីវ៉ាន់ច្រើនសង្កត់លើគ្នា
ដូច្នេះដើម្បីឲ្យប្រាកដថាសៀវភៅនោះគឺមានលំនឹង
ដើម្បីរក្សាលំនឹងសៀវភៅនៅក្នុងកេសក្រដាសនោះ ឬក៏ឡាំងក្រដាសនោះ គឺក្មេងប្រុសម្នាក់នោះ
គាត់ក៏បានយកក្រដាសកាសែតមកហែក បន្ទាប់មកគាត់ឆ្នូល បានន័យថាគាត់
បានន័យថាគាត់យកក្រដាសនោះមកធ្វើជាដុំតូចៗ តូចៗ ដើម្បីសៀតចូលទៅក្នុងចន្លោះ
ដែលមានពីសៀវភៅទៅនឹងក្រដាស ដើម្បីឲ្យវាណែនល្អ អញ្ចឹងគាត់ធ្វើបែបនេះ
ដើម្បីឲ្យសៀវភៅណែនល្អទៅនឹងឡាំងក្រដាសនោះ ដើម្បីកុំឲ្យសៀវភៅក្រឡុកនៅក្នុងឡាំងក្រដាស
ឬក៏ដើម្បីកុំឲ្យរលុង អញ្ចឹងនៅពេលដែលគេដឹកជញ្ជូន គឺវានឹងមានលំនឹងនៅក្នុងឡាំងក្រដាស
អញ្ចឹងវាអត់ធ្វើឲ្យខូចសៀវភៅ ឬក៏អត់ឲ្យធ្វើ ធ្វើអត់ឲ្យធ្វើឲ្យខូចប្រអប់នោះទេ
ដូច្នេះនៅពេលដែលយើងចង់ផ្ញើសម្ភារៈ ឬក៏ចង់ផ្ញើអីវ៉ាន់
នៅពេលដែលអីវ៉ាន់របស់យើងតូចជាងប្រអប់ យើងត្រូវយកអ្វីផ្សេងៗ ដូចជាក្រណាត់
ឬក៏ក្រដាសមកសៀតវាឲ្យណែន ដើម្បីងាយស្រួលក្នុងការផ្ញើអីវ៉ាន់។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ បន្ទាប់ពីគាត់សៀតណែនហើយ
អីវ៉ាន់របស់គាត់សៀតណែនចូលទៅក្នុងប្រអប់នោះហើយ អញ្ចឹងគាត់ក៏បានប្រើប្រាស់ស្កុត
ដើម្បីរុំឡាំងក្រដាសរបស់គាត់ឲ្យជាប់តែម្តង អញ្ចឹងគាត់បានបិទមាត់ឡាំងក្រដាសរបស់គាត់
គាត់បានបិទ បន្ទាប់មកគាត់យកស្កុតមករុំ គាត់យកស្កុតដែលមាននៅលើតុ
ដែលជារបស់ការិយាល័យប្រៃសណីយ៍ដែលទុកឲ្យប្រើនោះ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់យកមកបិទនៅលើមុខតំណរបស់ឡាំងក្រដាសនោះ
បានន័យថានៅពេលដែលយើងបិទគម្របឡាំងក្រដាស ឬក៏ប្រអប់តែងតែមានមុខតំណមួយ
អញ្ចឹងគាត់យកស្កុតមកបិទលើមុខតំណនោះ ដើម្បីឲ្យប្រាកដថាកុំឲ្យមុខតំណនោះហើប
ព្រោះនៅពេលដែលផ្ញើ នៅពេលដែលហើប អាចអីវ៉ាន់ខ្ទាយចេញពីប្រអប់ ដូច្នេះគាត់ត្រូវបិទឲ្យជិត
និងឲ្យបានជាប់ល្អបំផុត ដើម្បីការពារកុំឲ្យអីវ៉ាន់របស់គាត់មានការខូចខាត ឬក៏ខ្ទាយចេញពីប្រអប់។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ យើងឃើញបន្ទាប់ពីគាត់បិទស្កុតរួចរាល់ហើយ
គាត់បានបិទស្កុតលើប្រអប់របស់គាត់រួចរាល់ហើយ គាត់ក៏បានយកខ្សែមកចងបន្ថែមទៀត
អញ្ចឹងដោយសារតែស្កុត ពេលខ្លះគាត់ខ្លាចស្កុតរបស់គាត់របូត ឬក៏ស្កុតបិទអត់ជាប់
អញ្ចឹងវាអាចធ្វើឲ្យប្រអប់របស់គាត់ខូចខាត ឬក៏អាចធ្វើឲ្យសៀវភៅរបស់គាត់ខ្ទាយចេញពីប្រអប់
ដូច្នេះបន្ទាប់ពីគាត់បិទស្កុតរួចរាល់ហើយ គាត់ក៏បានយកខ្សែមកចងបន្ថែមពីលើមួយដងទៀត
ឬក៏បន្ថែមពីលើមួយជាន់ទៀត ដើម្បីឲ្យប្រាកដថាប្រអប់របស់គាត់គឺមានសុវត្ថិភាពនិងរឹងមាំល្អ
គឺអត់នឹង អត់ងាយខូចខាត ឬក៏អត់ងាយខ្ទាយ ឬក៏អត់ងាយរហែកនោះទេ
នៅពេលដែលគេដាក់អីវ៉ាន់គរលើគ្នាច្រើន ដោយសារតែនៅក្នុងការិយាល័យប្រៃសណីយ៍
គឺមានអីវ៉ាន់ច្រើនដែលត្រូវផ្ញើចេញម្តងៗ ដូច្នេះអីវ៉ាន់ទាំងអស់នឹងត្រូវដាក់គរលើគ្នា សង្កត់លើគ្នា
អញ្ចឹងប្រសិនបើយើងធ្វើឲ្យប្រអប់យើងអត់មាំទេ គឺវាអាចនឹងខូចខាត ដូច្នេះបុរសម្នាក់នេះ
បន្ទាប់ពីគាត់បិទស្កុតទៅលើប្រអប់របស់គាត់យ៉ាងជាប់ហើយ
គាត់ក៏បានយកខ្សែមករុំពីលើមួយជាន់ទៀត ដើម្បីឲ្យប្រាកដថាប្រអប់របស់គាត់គឺរឹងមាំល្អ។

បន្ទាប់មកទៀតរូបភាពទី ១៧ រូបភាពទី ១៧ គឺមិនខុសពីសំបុត្រនោះទេ
មិនខុសពីការផ្ញើសំបុត្រនោះទេ គឺបុរសម្នាក់នោះ គាត់ត្រូវសរសេរអាសយដ្ឋានរបស់អ្នកទទួល
អញ្ចឹងគាត់ត្រូវសរសេរឈ្មោះ អាសយដ្ឋាន ក៏ដូចជាលេខទូរស័ព្ទរបស់អ្នកទទួល
ដើម្បីឲ្យអ្នករត់សំបុត្រងាយស្រួលនៅក្នុងការយកទៅឲ្យអ្នកទទួលឲ្យចំគោលដៅ
អញ្ចឹងបុរសម្នាក់នោះ គាត់ក៏បានកំពុងតែកាន់ប៊ិច គាត់កាន់ប៊ិចសរសេរអាសយដ្ឋាន
ក៏ដូចជាឈ្មោះរបស់អ្នកទទួល នៅលើប្រអប់បញ្ញើរបស់គាត់ ដើម្បីមុននឹងគាត់ផ្ញើ
ព្រោះគាត់សរសេរបែបនេះ គឺងាយស្រួល ធ្វើឲ្យការិយាល័យប្រៃសណីយ៍
ឬក៏បុគ្គលិកការិយាល័យប្រៃសណីយ៍ យកអីវ៉ាន់នោះ ឬក៏យកសម្ភារៈ ឬក៏សៀវភៅរបស់គាត់នោះ
ទៅឲ្យមិត្តភក្តិរបស់គាត់ចំគោលដៅតែម្តង អញ្ចឹងគាត់ត្រូវសរសេរឲ្យបានច្បាស់
គាត់ត្រូវសរសេរឲ្យបានច្បាស់ ដើម្បីកុំឲ្យមានការភាន់ច្រឡំ ដូច្នេះគាត់
យើងឃើញនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែសរសេរដោយយកចិត្តទុកដាក់ជាទីបំផុត
ដោយគាត់កាន់ប៊ិចនៅក្នុងដៃស្តាំ ហើយសរសេរ ដៃឆ្វេងរបស់គាត់គឺដាក់នៅលើប្រអប់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីទប់កុំឲ្យប្រអប់របស់គាត់រង្គើ នៅពេលដែលប្រអប់រង្គើគឺវាពិបាកសរសេរ ដូច្នេះគាត់ទប់ឲ្យនឹង ឲ្យប្រអប់របស់គាត់មានលំនឹង ដើម្បីងាយស្រួលក្នុងការសរសេរ។

បន្ទាប់មកទៀតរូបភាពទី ១៨ នៅក្នុងរូបភាពទី ១៨
យើងឃើញបន្ទាប់ពីគាត់វេចខ្ចប់អីវ៉ាន់របស់គាត់ហើយ
វេចខ្ចប់សៀវភៅរបស់គាត់ចូលទៅក្នុងប្រអប់ហើយ
បន្ទាប់មកគាត់ក៏យកប្រអប់នោះមកឲ្យបុគ្គលិកនៅក្នុងការិយាល័យប្រៃសណីយ៍ម្តងទៀត
អញ្ចឹងបុគ្គលិកនោះ បន្ទាប់ពីទទួលបានប្រអប់ គាត់ក៏យកប្រអប់នោះទៅថ្លឹង
ដោយសារតែការផ្ញើអីវ៉ាន់គឺគេគិតតម្លៃទៅតាមគីឡូ ទៅតាមគីឡូ ឬក៏ទៅតាមទម្ងន់របស់សម្ភារៈ
ឬក៏អីវ៉ាន់ដែលយើងចង់ផ្ញើ ដូច្នេះប្រសិនបើយើងសម្ភារៈ ឬក៏អីវ៉ាន់ដែលយើងផ្ញើនោះគឺធ្ងន់
អញ្ចឹងគេគិតតម្លៃថ្លៃ ប៉ុន្តែប្រសិនបើស្រាលគឺគេគិតតម្លៃថោក
អញ្ចឹងគេគិតតម្លៃទៅតាមទម្ងន់របស់សម្ភារៈដែលយើងចង់ផ្ញើ ដូច្នេះនៅពេលដែលគាត់វេចខ្ចប់ហើយ
បុគ្គលិកនៅក្នុងការិយាល័យប្រៃសណីយ៍នោះ គាត់ក៏យកអីវ៉ាន់របស់គាត់
យកអីវ៉ាន់របស់ក្មេងប្រុសម្នាក់នោះមកថ្លឹងនៅលើជញ្ជីងអេឡិចត្រូនិចមួយ
ដោយសារតែអីវ៉ាន់ខ្លះគឺស្រាលខ្លាំងពេក ដូច្នេះយើងអត់អាចថ្លឹងនៅលើជញ្ជីង
ដែលមានទ្រនិចនាឡិកាបានទេ ដូច្នេះគេត្រូវប្រើជញ្ជីងអេឡិចត្រូនិច
ព្រោះជញ្ជីងអេឡិចត្រូនិចគឺវាអាចថ្លឹងទម្ងន់សម្ភារៈដែលស្រាលបំផុតបាន
អញ្ចឹងគាត់ក៏បានដាក់កេសក្រដាស ឬក៏ដាក់ប្រអប់សៀវភៅនោះនៅលើជញ្ជីងអេឡិចត្រូនិចមួយ
ដើម្បីថ្លឹងទម្ងន់របស់វា។

បន្ទាប់មកទៀតរូបភាពទី ១៩ រូបភាពទី ១៩ បន្ទាប់ពីថ្លឹងទម្ងន់ហើយ
អញ្ចឹងបុរសដែលជាបុគ្គលិកនៅក្នុងការិយាល័យប្រៃសណីយ៍ បានសួរទៅក្មេងប្រុសម្នាក់នោះថា
តើគាត់ចង់ផ្ញើជាបញ្ញើឆាប់រហ័ស ឬក៏ជាបញ្ញើធម្មតា
ព្រោះជាទូទៅសេវាកម្មនៅក្នុងការិយាល័យប្រៃសណីយ៍គឺមានពីរ គឺបញ្ញើឆាប់រហ័ស
បញ្ញើឆាប់រហ័សបានន័យថាជាបញ្ញើដែលយើងផ្ញើទៅតាមយន្តហោះ
អញ្ចឹងគេអាចផ្ញើអីវ៉ាន់ហ្នឹងទៅតាមយន្តហោះ អញ្ចឹងវាមានរយៈពេលលឿន
អាចពេលខ្លះបញ្ញើឆាប់រហ័សគឺចំណាយពេលត្រឹមតែបីថ្ងៃ
ឬក៏ពីរថ្ងៃតែប៉ុណ្ណោះទៅកាន់ប្រទេសដែលជិត
ជាឧទាហរណ៍ដូចជាប្រសិនបើយើងចង់ផ្ញើអីវ៉ាន់ពីកម្ពុជាទៅកាន់ប្រទេសថៃ
អញ្ចឹងប្រសិនបើយើងយកបញ្ញើឆាប់រហ័ស គឺគេចំណាយរយៈពេលតែបីថ្ងៃតែប៉ុណ្ណោះ
ក៏ប៉ុន្តែប្រសិនបើយើងយកបញ្ញើយឺត បានន័យថាយើងយកបញ្ញើធម្មតាតាមរយៈកប៉ាល់

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងបញ្ញើធម្មតាគេនឹងផ្ញើអីវ៉ាន់របស់យើងតាមរយៈកប៉ាល់
អញ្ចឹងវាអាចនឹងចំណាយរយៈពេលមួយសប្តាហ៍ទៅពីរសប្តាហ៍ដើម្បីទៅដល់គោលដៅ
ដូច្នេះនៅពេលដែលយើងចង់ផ្ញើអីវ៉ាន់ បុគ្គលិកដែលនៅការិយាល័យប្រៃសណីយ៍នឹងសួរយើងថា
តើយើងចង់ប្រើបញ្ញើឆាប់រហ័ស ឬក៏យើងចង់ប្រើបញ្ញើធម្មតា
អញ្ចឹងបញ្ញើឆាប់រហ័សគឺមានតម្លៃថ្លៃជាងបញ្ញើធម្មតាបន្តិច
ព្រោះថាបញ្ញើឆាប់រហ័សគឺគេប្រើប្រាស់យន្តហោះគឺលឿន ប៉ុន្តែបញ្ញើធម្មតាគឺគេប្រើប្រាស់កប៉ាល់
ហើយវាយឺត ដូច្នេះគឺមានតម្លៃថោក អញ្ចឹងក្មេងប្រុសម្នាក់នោះ
គាត់ក៏បានប្រាប់ទៅបុគ្គលិកការិយាល័យប្រៃសណីយ៍ថា គាត់ចង់បញ្ញើធម្មតា
បានន័យថាគឺផ្ញើតាមកប៉ាល់ ដោយសារតែគាត់អត់សូវមានលុយ ឬក៏គាត់អត់ចង់ចំណាយថវិកាច្រើន
ឬក៏អត់ចង់ចំណាយលុយច្រើននៅក្នុងការផ្ញើ ដូច្នេះគាត់ក៏បានផ្ញើតាមកប៉ាល់ គឺជាបញ្ញើធម្មតា
ឬក៏បញ្ញើយឺត។

បន្ទាប់មកទៀតរូបភាពទី ២០ នៅក្នុងរូបភាពទី ២០ យើងឃើញបន្ទាប់ពីគាត់ប្រាប់ថា
គាត់ចង់ផ្ញើបញ្ញើយឺតហើយ អញ្ចឹងគាត់ក៏បានហុចលុយទៅឲ្យបុគ្គលិកការិយាល័យប្រៃសណីយ៍
ហើយយើងឃើញនៅក្នុងរូបភាពនេះ
គឺគាត់កំពុងតែហុចលុយទៅឲ្យបុគ្គលិកនៅក្នុងការិយាល័យប្រៃសណីយ៍
ហើយបុគ្គលិកនៅក្នុងការិយាល័យប្រៃសណីយ៍ គាត់ក៏បានលូកដៃម្ខាងយកលុយ
ដៃម្ខាងទៀតគឺយកវិក្កយបត្រ អញ្ចឹងបុរសម្នាក់ហ្នឹង គាត់ក៏បានហុចវិក្កយបត្រ
ទៅឲ្យក្មេងប្រុសម្នាក់នោះ ដោយសារតែពេលខ្លះ
យើងត្រូវការតាមដានជាមួយនឹងការិយាល័យប្រៃសណីយ៍ ថាតើអីវ៉ាន់របស់យើង
ឬក៏បញ្ញើរបស់យើងបានទៅដល់អ្នកទទួលហើយឬនៅ
ដូច្នេះយើងត្រូវតាមដានដោយយើងខលទូរស័ព្ទការិយាល័យប្រៃសណីយ៍
តាមរយៈវិក្កយបត្រដែលយើងបានទទួល ហើយពេលខ្លះយើងអាចខលទៅសួរអ្នកដែលទទួល
ថាតើគាត់បានទទួលអីវ៉ាន់ហើយឬនៅ ព្រោះពេលខ្លះអាចបាត់បង់ របស់អាចបាត់បង់
ដូច្នេះការិយាល័យប្រៃសណីយ៍នឹងសងយើងជាថវិកាវិញ
ឬក៏ជាប្រាក់វិញនៅពេលដែលមានការបាត់បង់ អញ្ចឹងរាល់ការបាត់បង់ ឬក៏ការខូចខាត
ការិយាល័យប្រៃសណីយ៍នឹងទទួលសងយើងវិញ
ប្រសិនបើអីវ៉ាន់របស់យើងអត់បានទៅដល់ដៃរបស់អ្នកទទួលនោះទេ
ដូច្នេះគឺយើងត្រូវមានវិក្កយបត្រមួយ ដើម្បីមកបង្ហាញ ដើម្បីបញ្ជាក់ នៅពេលដែលយើង
អីវ៉ាន់របស់យើងត្រូវបានបាត់បង់ ឬក៏ខូចខាត ដើម្បីយើងទទួលសំណងពីការិយាល័យប្រៃសណីយ៍
ដូច្នេះហើយ នៅពេលដែលយើងផ្ញើ ខាងការិយាល័យប្រៃសណីយ៍តែងតែឲ្យនូវវិក្កយបត្រមួយ

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដើម្បីមកឲ្យយើងទុក ឬក៏ដើម្បីមកឲ្យយើងតាមដានជាមួយនឹងការិយាល័យប្រៃសណីយ៍ ថាតើអីវ៉ាន់របស់យើងផ្ញើបានទៅដល់គោលដៅហើយឬនៅ។

Copyright © 2017 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.